ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...០០២.....សហវ....វិសហ

# សេចក្តីជូនដំណឹង

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដោយទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាលនឹងធ្វើការប្រឡងជ្រើសរើសមន្ត្រីរាជការចំនួន ៣០០ នាក់ ដើម្បីមកបម្រើការងារក្នុងក្របខ័ណ្ឌអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ បេក្ខជនទាំងពីរភេទនឹងត្រូវជ្រើសរើស តាមរយៈការប្រឡងប្រជែង និង ត្រូវមានលក្ខណៈសម្បត្តិដូចតទៅៈ

**១.** មានសញ្ញាបត្របរិញ្ញាបត្រឡើងទៅសម្រាប់មន្ត្រីក្របខ័ណ្ឌ **ក**, មានសញ្ញាបត្រមធ្យមសិក្សាបត្រភាគទី ២ បូក ២ ឆ្នាំសិក្សាក្នុងគ្រឹះស្ថានឧត្តមសិក្សា សម្រាប់មន្ត្រីក្របខ័ណ្ឌ **ខ** និង មានសញ្ញាបត្រមធ្យមសិក្សាបត្រភាគទី ២ សម្រាប់មន្ត្រីក្របខ័ណ្ឌ **គ** ។

**២.** មានចំណេះដឹងទូទៅផ្នែកព័ត៌មានវិទ្យា, គណនេយ្យ, សេដ្ឋកិច្ច, ហិរញ្ញវត្ថុ ច្បាប់ និង ភាសាបរទេស (បារាំង ឬ អង់គ្លេស) ។

**៣.** មានការអនុញ្ញាតពីអង្គភាពសាមីឱ្យមកចូលរួមការប្រឡងប្រជែង និង ឯកភាពឱ្យផ្ទេរ ភារកិច្ចមកបម្រើការងារនៅក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៅពេលដែលបេក្ខជនប្រឡងជាប់ក្នុងករណីបេក្ខជនជាមន្ត្រីរាជការស៊ីវិល ។

**៤.** យល់ព្រមទទួលយកតួនាទី និង ភារកិច្ចតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

សេចក្តីដូចបានជម្រាបជូនខាងលើ ប្រសិនបើនិស្សិត និង សាធារណៈជនមានបំណងចូលរួមការប្រឡងជ្រើសរើសនេះ សូមអញ្ជើញមកទំនាក់ទំនង ដើម្បីសាកសួរលក្ខខណ្ឌ និង ទទួលព័ត៌មាន លម្អិត ព្រមទាំងបំពេញសំណុំបែបបទនៅ **វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ រហូតដល់ **ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១១** ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១១

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com